www.khmerpostusa.com
សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA

Free Copies
Vol. 13. Issue #294
May 29th, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

លោក ហ៊ុន សែន ពុំបានធ្វើសង្គ្រាមរួមទេ
សូមអាននៅទំព័រទី ០៧



ទីក្រុងបើកឡើងវិញ នៅថ្ងៃទី២៥ ឧសភា
សូមអាននៅទំព័រទី ០៨



ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ
សូមអាននៅទំព័រទី ១៥



# ប្រទេសចិនធ្លាក់ក្នុងវិបត្តិនៅពេលវាគទីជាមហាអំណាច

ដោយ ពិន សំខុន

មហាសន្និបាតចិនកុម្មុយនីស្ត ដឹកនាំដោយ ប្រធានាធិបតី ស៊ី ជីនពីង ដ៏មហិមា បានបញ្ចប់ទៅដោយជោគជ័យ កាលពីសប្ដាហ៍មុន ប៉ុន្តែវាក៏ជាឱកាស ដែលគេអាចដឹងថា ចិនមុខជានឹងឆ្លងកាត់វិបត្តិ **សូមអាននៅទំព័រទី០២**



លោក ជូ អេនឡាយ



លោក តេង ស៊ាវពីង



ប្រធានាធិបតី ស៊ី ជីនពីង ភរិយា

## “កូវីដ១៩”មិនទាន់បាត់ភ័យផង ក្រុងបើកឡើងវិញថ្ងៃទី២៥ ឧសភា

ដោយ ពិន សំខុន

លោក ឆលី បេគើ អភិបាលរដ្ឋម៉ាសាឈូ សិត បានប្រកាសតាមទូរទស្សន៍ កាលពីថ្ងៃចន្ទមុនថា ឱ្យបើកចរាចរនឹងរកស៊ីបានវិញនៅថ្ងៃទី២៥ឧសភា២០២០បន្ទាប់ពីបានបញ្ជាឱ្យបិទចំនួន ២ខែមកហើយ ដើម្បីទប់ស្កាត់ការរាលដាលជម្ងឺអាអាសន្នរោគរាតត្បាត“កូវីដ១៩”។ ការបើកឡើងវិញនេះ សម្រាប់អាជីវកម្មដែលគេហៅថា “មិនចាំបាច់”មានហាងកាត់សក់ ធ្វើក្រចកហាងលក់មាស ហាងលក់ទូរស័ព្ទ... ។ល។ រីឯ ហាងលក់ចំណីអាហារ លក់បន្លែបង្ការត្រីសាច់ គេមិនបានហាមប្រាមពីមុនមកទេ ក៏នៅបន្តដោយ ត្រូវគោរពបទដ្ឋានលក់ទំនិញបែបថ្មី តម្រូវឱ្យម្ចាស់ហាងរៀបចំកុំឱ្យភ្ញៀវ **សូមអានទំព័រទី ០៣**





មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL
សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987
Excellent Service Since 1987
គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា
Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense
សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា និងបន្តបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ
Thank you for your continued confidence
In our office to handle your legal and tax matters.
We look forward to serving you well into the future.
16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# ប្រទេសចិនធ្លាក់ក្នុងវិបត្តិនៅពេលវាតទីជាមហាអំណាច

ដោយ ពិន សំខុន

មហាសន្និបាតចិនកុម្មុយនីស្ត ដឹកនាំដោយ ប្រធានាធិបតី ស៊ី ជីនពីង ដ៏មហិមា បានបញ្ចប់ទៅដោយជោគជ័យ កាលពីសប្តាហ៏មុន ប៉ុន្តែវាក៏ជាឱកាស ដែលគេអាចដឹងថា ចិនមុខជានឹងឆ្លងកាត់វិបត្តិ ដ៏ធំធេងមួយ ដែលបណ្តាលមកពី១មហិច្ឆិតាជាមហាអំណាចត្រួតត្រាពិភពលោក ២ ជាប្រទេសកុម្មុយនីស្ត ដ៏ឆ្អិនឆ្អៅដែលមកដល់ចុងបញ្ចប់នៃរបបផ្តាច់ការនិយម ។

ប្រមាណជា១០ឆ្នាំចុងក្រោយនេះ បន្ទាប់ពីចិនរកស៊ីមានបានយ៉ាងកាក់កបហើយនោះ ក៏មានមហិច្ឆិតាត្រួតត្រាពីភពលោកជំនួសសហរដ្ឋអាមេរិកភ្លាមដែរ ។ តាមពិតទៅចិនបានពង្រីកមហិច្ឆិតានោះ តាំង ពីឆ្នាំ ១៩៦០មកម្ល៉េះ នាជំនាន់ ប្រធានាធិបតី ម៉ៅ សេ ទុង នឹងនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដែលផ្តួងផ្តើមសកម្មភាពចងក្រងប្រទេសក្រីក្រក្នុងពិភពលោកឱ្យនៅជាមួយគ្នាជា "ប្រទេសមិនចូលបក្សសម្ព័ន្ធ" សម្រាប់ឈរជើងនៅអង្គការសហប្រជាជាតិ, ពេលនោះមានថ្នាក់ដឹកនាំនៃប្រទេសពីរជាមេអណ្តើក ទី១ សម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋកម្ពុជា ជាមេអណ្តើកនៅខាងប្រទេសអាស៊ី និង ទី២ លោក នីកូឡា ឆាវឆេស្គូ ជាប្រធានាធីបតីនៃប្រទេសរ៉ូម៉ានី ជាមេអណ្តើកសម្រាប់ប្រទេសអឺរ៉ុបកណ្តាលខាងកើត ។ ប្រទេសជាច្រើននៅអាហ្វ្រិកនៅអាស៊ី នៅអឺរ៉ុប កណ្តាលនឹងខាងកើត បានចូលរួម "ប្រទេសមិនចូលបក្សសម្ព័ន្ធ" ដែលមានរូបភាពជាប្រទេសអព្យាក្រឹត្យ តែតាមពិតនោះជាប្រទេសទទួលជំនួយពីប្រទេសចិនកុម្មុយនីស្តសោះ ។


លោក ជូ អេនឡាយ


លោក តេង ស៊ាវពីង


ប្រធានាធិបតី ស៊ី និង ភរិយា


អតីតប្រធានាធិបតីរ៉ូម៉ានី


សម្តេចន.រ សីហនុ

មកដល់រជ្ជកាលលោកប្រធានាធិបតី តេង ស្វាវពីង, ចិនបានបើកទ្វារសេដ្ឋកិច្ច តាមរយៈ "សន្និសញ្ញាផ្សារ សេរីឱឆ្នាំ១៩៩០ ទទួលយកការងារមកឱ្យពលរដ្ឋចិនធ្វើក្នុងតម្លៃពលកម្មថោកពីក្រៅប្រទេសបានយ៉ាងក្រាស់ក្រែល ។ ឧស្សាហកម្មនៅអឺរ៉ុបនៅអាមេរិកក៏ហូរចូលទៅចិនយ៉ាងគគ្រឹកគគ្រេងធ្វើឱ្យចិនញញឹមបិទមាត់មិនជិត ពីព្រោះរូបិយប័ណ្ណចូលច្រើនពេក ។ ដូច្នេះនៅរជ្ជកាលបន្ទាប់នៃលោកប្រធានាធិបតី ស៊ី ជិនពីង គេយកលុយដែលរកបានទៅកសាងអាវុធ យុទ្ធភ័ណ្ឌទំនើប សម្រាប់កងទ័ពជើងទឹកជើងគោក នឹងជើងអាកាស, ហើយក៏ផ្តើមវាតទឹក វាតដីកោះ តាមសមុទ្រចិនខាងត្បូង, ធ្វើផ្លូវសេដ្ឋកិច្ចចិន តាមគម្រូ "ផ្លូវលក់ទំនិញសូត្រ" របស់ចិន កាលពីអតីតកាល ខ្វាត់ខ្វែងពេញពិភពលោក។ ផ្លូវនោះ សង់ ឡើងតាមប្រទេសនានា ដោយថវិការរបស់ចិន បានបង្កើតអស្ថិរភាព

តទៅទំព័រទី១១


ឥណទានផ្ទះ (ការខ្ចីសម្រាប់ទិញផ្ទះ)

✓ កម្មវិធីឥណទានទិញ និងការបង់ឡើងវិញ
✓ កម្មវិធីអ្នកទិញផ្ទះលើកដំបូង
✓ នឹងអាចមានទៅបាននូវកម្មវិធីអត្រាគង់ និងអត្រាផ្លាស់ប្តូរ
✓ ឥណទានអាស្រ័យតាមតម្លៃផ្ទះ
✓ ឥណទានសម្រាប់ការសាងសង់ទៅជាការខ្ចីរហូត



មជ្ឈមណ្ឌលនិក្ខេប
នៅធនាគារអេនធ័រប្រែស៍

978-656-5653 | 877-671-2265

ដាក់ពាក្យតាមអិនធឺណិតនៅ EnterpriseBanking.com/Mortgage

EnterpriseBanking.com/Mortgage

Enterprise Bank
CREATE SUCCESS

Member FDIC

# “កូវីដ១៩”មិនទាន់ចាញ់ភ័យផង ក្រុងបើកឡើងវិញថ្ងៃទី២៩ ឧសភា

ដោយ ពិន សំខុន


លោកអភិបាលរដ្ឋ ឆលី បេគើ

លោក ឆលី បេគើ អភិបាលរដ្ឋម៉ាសាឈូសិត បានប្រកាសតាមទូរទស្សន៍ កាលពីថ្ងៃចន្ទមុនថា ឱ្យបើកចរាចរនឹងរកស៊ីបានវិញ នៅថ្ងៃទី២៩ឧសភា២០២០ បន្ទាប់ពីបានបញ្ជាឱ្យបិទចំនួន២ខែមកហើយ ដើម្បីទប់ស្កាត់ការរាលដាលជម្ងឺអាអាសន្នរោគរាតត្បាត"កូវីដ១៩"។ ការបើកឡើងវិញនេះ សម្រាប់អាជីវកម្មដែលគេហៅថា"មិនចាំបាច់"មានហាងកាត់សក់ ធ្វើក្រចក ហាងលក់មាស ហាងលក់ទូរស័ព្ទ...។ល។ រីឯហាងលក់ចំណីអាហារ លក់បន្លែបង្គារត្រីសាច់ គេមិនបានហាមប្រាមពីមុនមកទេ ក៏នៅបន្ត ដោយត្រូវគោរពបទបាំនលក់ទំនិញបែបថ្មី តម្រូវឱ្យម្ចាស់ហាងរៀប ចំកុំឱ្យភ្ញៀវ នៅជិតគ្នាតិចជាង២ម ឱ្យពាក់របាំងមុខ នឹងការពារដោយរនាំងកញ្ចក់ រវាងអ្នកលក់នឹងអ្នកទិញ...។

សហរដ្ឋអាមេរិក ឋិតនៅក្នុងចំណោមប្រទេស ដែលមានអ្នកឆ្លងជម្ងឺកូវីដ១៩ ច្រើនជាងគេនៅក្នុងពិភពលោក។ ការនេះបណ្តាលឱ្យមានការបន្ទោសដល់ លោកប្រធានាធិបតី ឌុណលត្រាំ ថាលោកបានចាត់វិធានការទប់ស្កាត់ជម្ងឺរាតត្បាតនេះ យឺតពេលពេក, បើលោកចាត់វិធានការឱ្យទាន់ពេលវាមិនឆ្លងច្រើនដល់ម្លឹងទេ។

## ជំនួយ"ស្ទីមូលុសទី២"ជូនពលរដ្ឋអាមេរិ កាំងដល់ណាហើយ?

រីឯប្រាក់ជំនួយ"ស្ទីមូលុស"វិញ ក៏ដូចគ្នាមិនទាន់ទូទាត់បានគ្រប់គ្នាផងឥឡូវ"ស្ទីមូលុស"ទី២ គាត់តែងនឹងស្នើដោយដំណាងរាស្ត្រ "វ៉ាស៊ីដា តាឡេប និង ប្រមីឡា ជ័យផល បានចេញជាច្បាប់ ដែលមានឈ្មោះថា Heroes Act ។ បានអនុម័ត រួចហើយបញ្ជូនទៅព្រឹទ្ធសភា កាលពីសប្តាហ៏មុន។ នៅទីនោះព្រឹទ្ធសមាជិក ដែលភាគច្រើនជាសមាជិកគណបក្សសាធារណរដ្ឋ មិនចង់អនុម័តលើច្បាប់ដែលចង់ជួយប្រជាពលរដ្ឋក្រីក្រ ឬជាន់ទាបនោះទេ។ កាលពី"ស្ទីមូលុសទី១" លោកប្រធានាធិបតី ត្រាំ ដែលមកពីគណបក្សសាធារណរដ្ឋដូចគ្នាបានយកលុយទៅចែកឱ្យតែអាជីវករធំៗ រហូតដល់អស់លុយ ហើយចែកមកអាជីវករតូចៗមិនដល់ រហូតដល់ទៅសុំលុយបន្ថែម ទើបមានពាណិជ្ជករតូចខ្លះៗ ទទួលប្រាក់ជំនួយនោះបាន។

លោក វ៉ាសនា នួន ក្រុមប្រឹក្សាក្រុងឡូវែល


វ៉ាសនា នួន


ខេមរា ខៃ

បាននិយាយថា លើកនេះប្រ
ាក់"៣ទ្រីល្យុង"បាន ត្រូវស្នើជាលើក-
ទី២ដោយគណបក្សប្រជាធិប តេយ្យ ចែងយ៉ា
ងច្បាស់ថា"ត្រូវតែចែកឱ្យដល់អាជីវករតូចៗជ
ាមុន, ហេតុនេះហើយបានជា
ចំនួនលុយនឹងគោលដៅសំដៅទៅមូលដ្ឋានមានសារៈសំខាន់សម្រាប់ស្តារសេដ្ឋកិច្ចឡើងវិញ"។សម្រាប់ជាព្រឹទ្ធសមាជិក មីក ម៉ាក់ខណុល ប្រធានខាងគណបក្សសាធារណរដ្ឋនៅព្រឹទ្ធសភា បានពន្យាពេល មិនចង់ច្បាប់នេះចេញរួចរបៀបនេះទេ។

លោក ខេមរា ខៃ ដំណាងគណបក្សសាធារណរដ្ឋនៅឡូវែលនេះដែរនិយាយថា"ច្បាប់នេះនឹងត្រូវកែប្រែ ហើយអនុម័តដោយព្រឹទ្ធសមាជិក២ភាគ៣ គឺចំនួន៦៧រូប មិនមែនជារឿងធ្វើនយោបាយទេ, សេដ្ឋកិច្ចអាមេរិកាំង បានរង្គោះរង្គើដោយមានអ្នកអត់ការធ្វើ៣៨លាន ហើយហាងជាច្រើនប្រហែលជាបើកមិនរួចវិញទេ ដូចនេះប្រាក់ជំនួយថ្មីនេះ ត្រូវទៅឱ្យចំគោលដៅនៃអ្នកដែលត្រូវការ"។

អ្នកវិភាគព័តិមាននិយាយថា "ចង់មិនចង់" ស្ទីមូលុសទី២"នោះនឹងចេញរួចពីព្រោះតែឱកាស បោះឆ្នោតនឹងមកដល់នៅខែវិច្ឆិកា ខាងមុខនេះ ហើយ ដូច្នេះគេតែងតែចង់បានគុណសម្បត្តិនាពេលនេះហើយ"។






# កម្ពុជាធ្វើកំណត់ទូតទៅវៀតណាមស្នើឱ្យរុះរើទីតាំងយោធាដែលបោះតង់នៅតំបន់ព្រំដែន មិនទាន់ឯកភាពគ្នាក្នុងភូមិសាស្ត្រខេត្តកណ្តាលជាបន្ទាន់

(ភ្នំពេញ)៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកមពុជា នាថ្មីៗនេះបានផ្ញើកំណត់ទូតមួយទៅកាន់ក្រសួងការបរទេសវៀតណាម ដើម្បីស្នើឱ្យរដ្ឋាភិបាល ប្រទេសវៀតណាម រុះរើទីតាំងយោធាទាំងអស់ចេញពីតំបន់ព្រំដែន ដែលតំបន់នោះពុំទាន់បានឯកភាពគ្នាលើខ្សែបន្ទាត់ព្រំដែនរវាងប្រទេសទាំងពីរនៅឡើយ។ កំណត់ទូតកម្ពុជានេះ បានធ្វើឡើងបន្ទាប់ពីយោធាវៀតណាមបានបោះតង់ចំនួន ៣១កន្លែង នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម រវាងស្រុកលើកដែក និងស្រុកកោះធំ ខេត្តកណ្តាល ទល់និងខេត្តអានយ៉ាង ដែលខ្សែបន្ទាត់ព្រំដែនចំណុចនេះ ពុំទាន់បានឯកភាពគ្នាឡើយ ដោយគណៈកម្មការចម្រុះព្រំដែនរវាងប្រទេសទាំងពីរ។ ការបោះតង់យោធានេះ បានធ្វើឡើងចាប់តាំងពីថ្ងៃទី១៨ខែមីនា ឆ្នាំ២០២០ មកម្ល៉េះ បន្ទាប់ពីវៀតណាមបានរឹតបន្តឹងចំពោះការឆ្លងដែនទៅកាន់ប្រទេសវៀតណាម ដែលជាវិធានការទប់ស្កាត់ការចម្លងជំងឺកូវីដ១៩។ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាលោក កុយ គួង បានថ្លែងប្រាប់អង្គភាពព័ត៌មាន Fresh News ឱ្យដឹងថា ពាក់ព័ន្ធនឹងករណីនេះអាជ្ញាធរកម្ពុជាធ្លាប់បានចុះទៅណែនាំ និងស្នើឱ្យយោធាវៀតណាមរុះរើចេញពីតំបន់នោះ ប៉ុន្តែមកទល់ពេលនេះភាគីវៀតណាម បានរុះរើតង់ចេញតែ ៣ទីតាំងប៉ុណ្ណោះ។ ដោយសារតែវៀតណាម-


ប៉ូលិសខ្មែរទប់ស្កាត់ការបោះជំរុំវៀតណាមនៅលើដីខ្មែរ

មិនទាន់ រើតង់យោធារបស់ខ្លួនទាំងអស់ចេញពីតំបន់មិនទាន់ឯកភាពគ្នាលើខ្សែបន្ទាត់ព្រំដែននៅឡើយនោះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ បានធ្វើកំណត់ទូតតវ៉ាទៅភាគីវៀតណាម ដែលមានខ្លឹមសារសំខាន់ដូចតទៅ៖

១៖ វត្តមានរបស់យោធាវៀតណាមនៅតាមបណ្តោយព្រំដែនដែលមិនទាន់បានឯកភាពគ្នា គឺបានរំលោភលើចំណុចទី៨ នៃសេចក្តីប្រកាសរួម កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៩៥ និងកថាខណ្ឌ៥ ប្រការ៣ នៃសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ២០០៥ និងកិច្ចព្រមព្រៀងព្រំដែននានា ដែលបានបញ្ចប់ការចរចាដោយភាគីកម្ពុជា និងវៀតណាម។

២៖ ស្នើឱ្យភាគីវៀតណាមរុះរើតង់ទាំងអស់ចេញ និងដកកម្លាំងយោធាចេញពីទីតាំងខាងលើ និងបញ្ឈប់នូវរាល់សកម្មភាពនានាជាបន្ទាន់ និងរក្សាបរិស្ថានភូមិសាស្ត្រនៅតំបន់ទាំងអស់នោះឱ្យដូចសភាពដើម រហូតដល់គណៈកម្មការចម្រុះព្រំដែន នៃប្រទេសទាំងពីរកំណត់ច្បាស់លាស់ខ្សែបន្ទាត់ព្រំដែននៅតំបន់ទាំងនោះ។

៣៖ ស្នើឱ្យវៀតណាមធានាថា សកម្មភាពបែបនេះនឹងមិនកើតឡើងជាដាច់ខាតក្នុងពេលអនាគត ដើម្បីរក្សាភាពជាអ្នកជិតខាងល្អមិត្តភាពជាប្រពៃណីដែលមានស្រាប់ និងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងពីរ។ ពាក់ព័ន្ធនឹងការបោះតង់របស់កងទ័ពវៀតណាមនៅលើព្រំដែនដែលមិនទាន់បានឯកភាពគ្នានេះ អភិបាលខេត្តកណ្តាល លោក គង់ សោភ័ណ្ឌ ក៏បានធ្វើលិខិតស្នើទៅកាន់ លោក ង្វៀន ថាញ់ប៊ិញ ប្រធានគណៈកម្មាធិការប្រជាជនខេត្តអានយ៉ាងរបស់វៀតណាមឱ្យមានវិធានការរុះរើតង់កៅស៊ូទាំងនោះចេញផងដែរ ដើម្បីរក្សាស្ថានភាពដដែលនៅតាមតំបន់ព្រំដែន ដែលប្រទេសទាំងពីរពុំទាន់បានឯកភាពគ្នាជាកិច្ចឆ្លើយតបលោកង្វៀន ថាញ់ប៊ិញ ប្រធានគណៈកម្មាធិ

តទៅទំព័រទី ១៣



មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ
ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare
and Other Health Insurances
Our Staff Speaks Khmer

# អត្ថប្រយោជន៍ភាពគ្មានការងារធ្វើ ពេលមានអាសន្នរោគរាតត្បាត

**ទិដ្ឋភាពទូទៅ:**

នៅថ្ងៃទី២៧ ខែមិនា ឆ្នាំ២០២០ CARES Act បានចុះហត្ថលេខាលើច្បាប់ដែលរួមមានការផ្តល់ជំនួយសង្គ្រោះដល់កម្មករដែលរងផលប៉ះពាល់ដោយច្បាប់ កូរ៉ូណាវីរុស ។ ផ្នែកទី ២១០២ នៃច្បាប់ CARES Act បង្កើតកម្មវិធីសហព័ន្ធបណ្តោះអាសន្នថ្មីមួយដែលមានឈ្មោះថា ជំនួយភាពគ្មានការងារធ្វើពេលមានអាសន្នរោគរាតត្បាត (Pandemic Unemployment Assistance,PUA) ដែលជាទូទៅផ្តល់អត្ថប្រយោជន៍ដល់អ្នកអត់ការងារធ្វើរហូតដល់៣៩ សប្តាហ៍ ដល់បុគ្គលដែលមិនមានសិទ្ធិទទួលបានប្រភេទនៃភាពអត់ការងារធ្វើផ្សេងទៀត។ ច្បាប់ស្តីពី CARES ក៏បង្កើតកម្មវិធីសហព័ន្ធបណ្តោះអាសន្នថ្មីមួយដែលមានឈ្មោះថា ជំនួយភាពគ្មានការងារធ្វើរោគរាតត្បាតសហព័ន្ធ (Federal Pandemic Unemplyment Assistance, FPUC) ដែលផ្តល់អត្ថប្រយោជន៍បន្ថែមចំនួន $600 ក្នុងមួយសប្តាហ៍ដល់អ្នកដែលមានសិទ្ធិទទួលបាន PUA ។

**សិទ្ធិទទួល:**

PUA ផ្តល់អត្ថប្រយោជន៍ភាពអត់ការងារធ្វើ ដល់បុគ្គលដែលមិនអាចធ្វើការបាន ដោយសារហេតុផលដែលទាក់ទងនឹង Covid-19 ប៉ុន្តែមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍អត់ការងារធ្វើជាប្រចាំ ឬយូរ ។ ដើម្បីមានសិទ្ធិទទួលបានបុគ្គលម្នាក់ៗត្រូវតែមានសមត្ថភាពធ្វើការ និងអាចរកការងារបានស្របតាមច្បាប់របស់រដ្ឋ ។

បុគ្គលដែលទទួលបានអត្ថប្រយោជន៍ពី PUA ដែលត្រូវបានកំណត់ថា មានសិទ្ធិទទួលបាន FPUC នឹងទទួលបានការទូទាត់អត្ថប្រយោជន៍បន្ថែមចំនួន$600 សម្រាប់សប្តាហ៍ដែលបញ្ចប់នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ ។

**របៀបដាក់ពាក្យសុំ**

កម្មករនៅរដ្ឋម៉ាសាឈូសេតអាចបំពេញពាក្យសុំ PUA ដោយចូលទៅកាន់គេហទំព័រ https://ui cares-act. mass.gov/PUA ។ អ្នកដាក់ពាក្យសុំនឹងត្រូវផ្តល់ព័ត៌មានដូចខាងក្រោម:

- លេខសន្តិសុខសង្គមរបស់អ្នក
- ប្រសិនបើអ្នកមិនមែនជាពលរដ្ឋអាមេរិកទេ លេខ A USCIS របស់អ្នក
- អាសយដ្ឋានលំនៅដ្ឋានរបស់អ្នក
- អាសយដ្ឋានប្រៃសនីយ (ប្រសិនបើខុសពីអាសយដ្ឋានលំនៅដ្ឋាន) របស់អ្នក
- លេខទូរស័ព្ទរបស់អ្នក
- លេខអ៊ីមែលរបស់អ្នក
- កាលបរិច្ឆេទកំណើតរបស់អ្នក
- ប្រាក់ឈ្នួលរបស់អ្នក ២០១៩ ដែលរួមមាន :
- ទម្រង់ 1099
- កន្ទុយសែក
- របាយការណ៍ធនាគារ
- របាយការណ៍ធនាគារ លេខសន្តិសុខសង្គមនិងថ្ងៃខែឆ្នាំកំណើតសម្រាប់កូនអាស្រ័យរបស់អ្នក។
- របាយការណ៍ធនាគារ ប្រសិនបើអ្នកចង់នាំ ប្រើប្រាក់កក់ដោយផ្ទាល់សម្រាប់ការទូទាត់គណនីធនាគារ និងលេខរបស់អ្នក។

**<u>ក្រោយពីពាក្យសុំ:</u>**

រាល់ពាក្យសុំដែលទទួលយកដំបូងនឹងទទួលបានចំនួនអត្ថប្រយោជន៍អប្បបរមាប្រចាំសប្តាហ៍ បូករួមនឹងអត្ថប្រយោជន៍បន្ថែមប្រចាំសប្តាហ៍របស់ FPUC ចំនួន $៦០០។ នៅពេលប្រាក់ឈ្នួលរបស់កម្មករត្រូវបានផ្ទៀងផ្ទាត់ចំនួនអត្ថប្រយោជន៍ប្រចាំសប្តាហ៍អាចនឹងកើនឡើង។ អត្ថប្រយោជន៍ប្រចាំសប្តាហ៍រួមទាំងការកើនឡើងនូវចំនួនអត្ថប្រយោជន៍ប្រចាំសប្តាហ៍របស់អ្នកនឹងមានដំណើរការឡើងវិញនៅសប្តាហ៍ដែលនឹងបញ្ចប់នៅថ្ងៃទី៨ ខែកុម្ភៈឆ្នាំ ២០២០ ឬកាលបរិច្ឆេទ ដែលអ្នកក្លាយជាអ្នកអត់ការងារធ្វើ ហេតុផលពាក់ព័ន្ធ COVID-19។

សូមបញ្ជាក់ថា ដំបូងប្រព័ន្ធនេះ អាចទូទាត់ប្រាក់អត្ថប្រយោជន៍បានត្រឹមសប្តាហ៍ដែលបញ្ចប់នៅ ថ្ងៃទី ១៤ ខែមីនាឆ្នាំ ២០២០ ។ ក្រោយមកកម្មករដែលមានសិទ្ធិនឹងអាចបញ្ជាក់ពីអត្ថប្រយោជន៍ ហើយនឹងអាចស្នើសុំប្រាក់រង្វាន់ម្តងទៀតរហូត២០២០ ប្រសិនបើកាលបរិច្ឆេទដល់សប្តាហ៍ ដែលបញ្ចប់នៅថ្ងៃទី ៨ ខែកុម្ភៈឆ្នាំ នៃភាពអត់ការងារធ្វើ ធ្វើឱ្យពួកគេមានសិទ្ធិទទួលបាន។

**<u>ប្តឹងឧទ្ធរណ៍</u>**

**ការប្តឹងឧទ្ធរណ៍នូវការប្តេជ្ញាចិត្តដំបូង**

ប្រសិនបើ DUA កំណត់ថា ធ្វើជងឺអ្នកមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍ជំនួយពីភាពអត់ការងារធ្វើជំងឺរាតត្បាត (Pandemic Unemployment Assistance) អ្នកនឹង ទទួលបានការដកសិទ្ធិតាមអេឡិចត្រូនិក។ អ្នកនឹងអាចប្តឹងឧទ្ធរណ៍នឹងអាចប្តឹងឧទ្ធរណ៍ដោយដកហូតសិទ្ធិដោយ 1) ចុចលើ "ខ្ញុំចង់ប្តឹង ឧទ្ធរណ៍" លើសេចក្តីជូនដំណឹង, ឬ ២) ស្នើសុំបណ្តឹងឧទ្ធរណ៍ទៅកាន់ភ្នាក់ងារមជ្ឈមណ្ឌលហៅតាមទូរស័ព្ទ។

តទៅទំព័រទី ១២

# PANDEMIC UNEMPLOYMENT ASSISTANCE BENEFITS

**Overview:**

On March 27, 2020, the CARES Act was signed into law, which includes the Relief for Workers Affected by Coronavirus Act. Section 2102 of the CARES Act creates a new temporary federal program called Pandemic Unemployment Assistance (PUA) that in general provides up to 39 weeks of unemployment benefits to individuals who are not eligible for other types of unemployment. The CARES Act also creates a new temporary federal program called Federal Pandemic Unemployment Assistance (FPUC) that provides an additional $600 weekly benefit to those eligible for PUA.

**Eligibility:**

PUA provides unemployment benefits to individuals who are unable to work because of a COVID-19-related reason but are not eligible for regular or extended unemployment benefits. To be eligible, individuals must be able to work and be available for work in accordance with state law.

Individuals receiving PUA benefits who are determined eligible for FPUC will receive an additional $600 benefit payment for the weeks ending April 4, 2020 to July 25, 2020.

**How to Apply:**

Massachusetts workers may complete a PUA application by visiting https://ui-cares-act.mass.gov/PUA/. Applicants will need to provide the following information:

• Your social security number
• If you are not a citizen of the United States, your USCIS A-number
• Your residential address
• Your mailing address (if different from residential address)
• Your telephone number
• Your email address
• Your birth date
• Your wage records for 2019, which includes:
- 1099 forms
- Pay stubs
- Bank statements
• The social security number(s) and date(s) of birth for your dependent child(ren)
• If you want to use direct deposit for payment, your bank account and routing numbers.

**After applying:**

All accepted applications will initially receive the minimum weekly benefit amount, plus an additional $600 FPUC weekly benefit. Once a worker's wages are verified, weekly benefit amounts may increase. Weekly benefits, including any increase to your weekly benefit amount, will be retroactive to the week ending February 8, 2020, or the date when you became unemployed, whichever is more recent, as long as you became unable to work because of a COVID-19 related reason.

Please note that, initially, the system can only pay benefits retroactively to the week ending March 14, 2020., Later, eligible workers will be able to certify for benefits, and will be able to request benefits retroactively to the week ending February 8, 2020, if their dates of unemployment make them eligible.

**Appeals:**

**Appealing an initial determination**

If DUA determines that you are not eligible to receive Pandemic Unemployment Assistance benefits, you will receive a disqualification electronically. You will be able to appeal the disqualification by 1) clicking on "I want to appeal" on the notice; or 2) requesting an appeal to a call-center agent by phone.

*You must appeal within 30 calendar days of the date of the disqualification.*

It is important that you participate in any scheduled hearing as the hearing will result in a new decision on your eligibility.

If you are still unemployed while waiting for a hearing, you must continue to request benefit payments each week. Even if your initial determination is reversed, you will not receive benefit payments for the weeks when you did not request benefits.

**Hearings**

When the Hearings Department receives the appeal, it will be scheduled for a hearing and you will be sent a notice of the date and time. Until DUA's offices are reopened to the public, hearings will be conducted exclusively by telephone.

Hearings are conducted by review examiners. After the hearing, the review examiner will issue a written decision based on documents and information presented at the hearing.

**Board of Review of the Department of Unemployment Assistance**

If you disagree with the review examiner's decision, you have 30 calendar days after the date of mailing of that decision to appeal to the Board of Review

If the Board of Review accepts the case for review, it will make a decision using the case material received from the Hearings Department, including the recorded hearing. When the Board of Review issues a decision, it provides instructions about how to appeal the decision to the District Court or the Boston Municipal Court. You can also appeal to the District Court or the Boston Municipal Court if the Board of Review declines to accept

Please Read Page 12

# មណ្ឌលពិនិត្យសុខភាពឡូវែល

# Lowell Primary Care Center

លោកវេជ្ជបណ្ឌិត មុី សុខារិទ្ធ, **M.D.**
**Sokharith Mey, M.D.**

លោក ចាន់ ទូច , **C.N.P.**
**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ
***Family Medicine***

&

សុខភាពផ្លូវចិត្ត
***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហ៊ែល. មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking

# លោក ហ៊ុន សែន ពុំបានធ្វើសង្គ្រាមរួមទេ(ត)

ដោយ ពិន សំខុន

ពិភពលោកបានធ្វើសកម្មភាពរួមគ្នា ដើម្បីកំចាត់ជម្ងឺអាសន្នរោគរាតត្បាត "កូវីដ១៩" យ៉ាងគួរឱ្យចាប់អារម្មណ៍លើកលែងតែកម្ពុជារបស់លោក ហ៊ុន សែន បានរក្សាកណ្តាប់ដៃដែកលើយុទ្ធនាការ ដូចគ្នានេះ ពុំមែនសម្រាប់ប្រយោជន៍ប្រជាពលរដ្ឋខ្មែរទេ តែសម្រាប់តែប្រទេសចិនតែប៉ុណ្ណោះ។

តើវិស័យអ្វីខ្លះដែលបង្ករខូចខាតលេចធ្លោជាងគេ?

វិស័យ "អនុគ្រោះពន្ធEBAរបស់សហភាពអឺរ៉ុប ចំពោះកម្ពុជា: "លោកនាយករដ្ឋមន្រ្តីខ្មែរ ហ៊ុន សែន សុខចិត្តទាត់ចោល EBA ដែលជាប្រភពសេដ្ឋកិច្ចចិញ្ចឹមកម្មករខ្មែរច្រើនម៉ឺននាក់ នៅលើលក្ខខណ្ឌការពារសិទ្ធិមនុស្សនៅក្នុងកម្ពុជា ដោយសង្ឃឹមថា ប្រទេសចិននឹងបោះដៃមកជួយខ្មែរនៅពេលដែលខ្មែរមានវិបត្តិកើតឡើង ។

វិស័យ "វិធានការទប់ទល់ការរាតត្បាតនៃជម្ងឺអាសន្នរោគកូវិដ១៩" ក៏រឹតតែមិនបានធ្វើអ្វីជាដុំកំភួនដោយមិនមានវិធានការរឹងប៉ឹងឱ្យមានអ្នកឯកទេសខាងពេទ្យគ្រប់គ្រាន់នៅតាមមន្ទីរពេទ្យ ឬមន្ទីរសង្គ្រោះបន្ទាន់ ឬបទបញ្ជាដែលច្បាស់ជាសង្គ្រោះមនុស្សបាន... បែរជារាយមាយបណ្តាលឱ្យមាន "ការមិនជឿលើភាពប្រុងប្រយ័ត្ន" ទៅវិញ។



លោក ហ៊ុន សែន



ព្រះមហាក្សត្រ សីហមុនី និងព្រះមាតា មុនីនាថ

គំនិត "បង្កើនភាពគ្រោះថ្នាក់ដល់ប្រទេសនឹងពលរដ្ឋ"ខ្លួនឯង ដោយអនុញ្ញាត្តិឱ្យទេសចរចិនមកពីវូហាន៣០០០នាក់ចូលមកកម្ពុជា នៅចុងខែវិច្ឆិកា នៅពេលដែលកូវិដ១៩ផ្តើមផ្ទុះចេញហើយ។ ការទៅធ្វើទស្សនកិច្ចនៅប្រទេសចិនខែមករា ២០២០, មិនដែលពាក់របាំងមុខការពារសុខភាពខ្លួនឯង ជាគំរូនៃមេដឹកនាំខ្វះចំណេះដឹងមិនខ្វល់ខ្វាយពីសុខភាពប្រជារាស្រ្ត, គំនិតទាំង ២នេះ គឺជាការយកចិត្តចិនយ៉ាងល្ងង់ខ្លៅជាទីបំផុត ។

មិនបានធ្វើឱ្យព្រះមហាក្សត្រមានភាពកក់ក្តៅ នឹងកិច្ចការពារ ដើម្បីឱ្យទ្រង់អាចគង់ប្រថាប់នៅក្នុងប្រទេសបាន ដើម្បីជាការចូលរួមស្លាប់រស់ជាមួយប្រជាជាតិ ដែលមានព្រះអង្គមានតួនាទីជា "ព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា"

មិនបានធ្វើឱ្យវិស័យព័តិមានខ្មែរក្លាយជាព័តិមានដែលគួរឱ្យជឿបានម្ល៉ោះហើយព័តិមានដែលផ្សព្វផ្សាយពីការវិវត្តិនៃកូវិដ១៩ នៅកម្ពុជាពុំមានអ្នកឆ្លងជម្ងឺថ្មី? ពុំបានជាជាជំនួយដល់ការទប់ស្កាត់ជម្ងឺអាសន្នរោគនោះទេ។

រដ្ឋាភិបាលមិនបានគ្រោងថា នឹងមានចំណាកស្រុករាប់សែននាក់ នឹងត្រឡប់មកកាន់មាតុប្រទេសវិញ នាឱកាសវិបត្តិកូរ៉ូណាវ៉ាយរ៉ុសនោះទេ ។ ជាមួយនឹងការបាត់បង់ការងារនៅកម្ពុជាដោយកូវីដ១៩,ដោយពាណិជ្ជករចិនចាកចេញពីកម្ពុជា, ដោយអំពើពុករលួយ, នឹងដោយអំណាចផ្តាច់ការនិយម...ធ្វើឱ្យភាពទុរភិក្សអត់ឃ្លាន ការបំពានសិទ្ធិមនុស្ស បានរីកធាត់ធំ ដោយគ្មានសេចក្តីរាយការសមរម្យណាមួយ ចេញមកក្រៅប្រទេសបានឡើយ។

សង្ឃឹមលើសមមិត្តចិន ចិនក៏ប្រទូស្តរាយជាមួយប្រទេសអាស៊ានស្ទើរតែទាំងអស់សល់តែខ្មែរម្នាក់, **តទៅទំព័រទី ១៣**




SWH
Senior Whole Health.
A MAGELLAN COMPANY

គម្រោងថែទាំសុខភាពសម្រាប់មនុស្សចាស់ជាមួយនឹងកម្មវិធី MassHealth ។

យើងនិយាយជាភាសារបស់អ្នក

យើងនិយាយបានជាង 40 ភាសា ហើយយើងនឹងជួយអ្នកឲ្យទទួលបានការថែទាំពីគ្រូពេទ្យដែលយល់អំពីអ្នក!

ស្វែងយល់បន្ថែម។ ហៅទូរស័ព្ទមក 1-888-566-3526 (TTY 711)។
www.seniorwholehealth.com

កម្មវិធី Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធដែលចូលជាធរមាន និងមិនធ្វើការរើសអើងដោយសារពូជសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិ សាសន៍ អាយុ ពិការភាព ឬភេទឡើយ។ កម្មវិធី Senior Whole Health (HMO SNP) និង Senior Whole Health NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលដែលមានកិច្ចសន្យា Medicare Advantage និងកិច្ចសន្យាជាមួយសហធនរដ្ឋ Massachusetts /កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យាពលំឆ្នាំ។
H2224-2020-84533 _M KHM Approved 2/11/2020

# ទីក្រុងបើកឡើងវិញថ្ងៃទី២៩ ឧសភា មានអ្វីប្លែកនៅឡូវែល?

ដោយ ពិន សំខុន

ការរាតត្បាតនៃជម្ងឺអាសន្នរោគ"កូវីដ១៩" នៅតែមានទំហុំធំធ្ងន់ធ្ងរនៅឡើយ តែគេនិយាយឡើង សាំុត្រចៀកទៅហើយ តាំងពី៣ខែមកហើយ។

ថ្វីត្បិតតែអភិបាលរដ្ឋម៉ាសាឈូសិត បានប្រកាស"ឱ្យបើកពាណិជ្ជកម្មវិញ នៅថ្ងៃទី ២៥ ឧសភា" ខាងមុខក៏ដោយគ្រូពេទ្យឯកទេសបាននិយាយថា ការបើកឱ្យដំណើរការសេដ្ឋកិច្ចប្រញាប់ពេកអាចនឹងបង្កឱ្យមានការផ្ទុះកូវិដ១៩ ជាលើកទី២ជាមិនខាន។ គ្រូពេទ្យខ្លះទៀត ព្យាករថាការផ្ទុះ កូវីដ១៩ នាថ្ងៃខាងមុខជាប្រាកដ ពីព្រោះស្ថិតិដែលបានផ្តល់ជាសាធារណៈនោះ មិនឆ្លុះបញ្ចាំង ការពិតទេ ដោយសារតែក្រសួងមិនបានរាប់អ្នក"ស្លាប់នៅផ្ទះ"នោះទេ។

មុនពេលអនុញ្ញាត្តិឱ្យ"ប៊ីសនិស មិនចាំបាច់" អាចបើកវិញបាន នាថ្ងៃទី២៥ខាងមុខនោះ តែក៏មាន "ហាងចាំបាច់"នៅឡូវែល មួយចំនួន ក៏បានបិទទ្វារហើយបើកទ្វារបំរើភ្ញៀវ ខ្លះទៅហើយដែរ។

១ ភោជនីយដ្ឋាន ខ្មែរ Simply Khmer មិនដែលបានបិទទ្វារទេ ក្រៅតែពីថ្ងៃបិទទ្វារសម្រាកធម្មតា នៅថ្ងៃចន្ទ នឹង អង្គារ ប៉ុន្តែ ភ្ញៀវមិនអាចអង្គុយហូបក្នុងហាងបានទេ ត្រូវបញ្ជា




ទិញម្ហូបយកទៅផ្ទះ, មិនឱ្យមានភ្ញៀវចំនួនច្រើនចូលក្នុងហាង នាពេលតែមួយទេ ហើយត្រូវតែពាក់របាំងមុខថែមទៀតផង។ ដោយសារមិនដែលបិទទ្វារ ទោះជាមិនឱ្យចូលអង្គុយហូបក្តីលោកសម្បត្តិជាម្ចាស់ភោជនីយដ្ឋាននិយាយថា"មានអតិថិជន ៥០ ទៅ ៦០% ប្រៀបធៀបទៅនឹងភ្ញៀវពេលមុន"កូវីដ១៩" ចូលមកទិញ ម្ហូប អាហារដែរ។

២-ភោជនីយដ្ឋាន"កូឡាបក្រហម" បានបិទទ្វារមួយរយៈដែរ តែនៅពេលបើកមកវិញកាលពី២សប្តាហ៍មុន ក៏ត្រូវអនុវត្តិច្បាប់ទប់ស្កាត់កូវីដ១៩ ដូចគ្នាដែរ គឺមិនឱ្យហូបក្នុងហាង មិនអនុញ្ញាតិឱ្យមនុស្សចូលច្រើនគ្នាក្នុងពេលតែមួយ ហើយត្រូវពាក់"ម៉ាស់"ចូលទៅបញ្ជាទិញម្ហូប។




៣-ភោជនីយដ្ឋានភ្នំពេញ ទើបចាប់ផ្តើមបើកឡើងវិញបាន១សប្តាហ៍ហើយ បន្ទាប់ពីរដ្ឋគេបិទក្រុង តាំងតែពីដំបូងមក ទោះបីជាភោជនីយដ្ឋានបានត្រូវចាត់ទុកថា ជា"ពាណិជ្ជកម្មចាំបាច់"ក៏ដោយ។ នៅពេលបើកមកវិញ ភ្ញៀវផ្តើមមកបញ្ជាទិញម្ហូបមួយៗពីព្រោះមិនទាន់ទម្លាប់ថា ហាងនេះ បានបើកមកវិញហើយនោះ ។ ម្ចាស់ហាងបាននិយាយថា មិនទាន់ហៅបុគ្គលិកទាំងអស់ឱ្យត្រឡប់មកវិញ នៅឡើយទេ ពីព្រោះឥតមានការឱ្យធ្វើ។

៤-ភោជនីយដ្ឋានឡូវែល ស្ថិតនៅ "ប៉ៃលិនប្លូស្នា"ជាភោជនីយដ្ឋានខ្មែរ ខ្នាតធំមួយដែរ ក៏មិនបានបិទទ្វារ ជារហូតមក តាំងពីមានបញ្ជា




ឱ្យបិទក្រុង នាពាក់កណ្តាលខែ មិនា២០២០ មក។

៥-ផ្សារអមរាជាGrocery នៅជាប់គ្នានឹងភោជនីយដ្ឋានឡូវែល ក៏មិនបានបិទទ្វារ ហើយនៅតែបំរើអតិថិជន ក្នុងរយៈពេលដែលមានការហាមឃាត់ដែរ ពីព្រោះជាហាងលក់គ្រឿងបរិភោគ គឺជា"ពាណិជ្ជកម្មចាំបាច់"។

៦-ផ្សារបាយ័ន Bayon Market នៅតំបន់ប៉ៃលិនបានបិទទ្វារមួយរយៈ **តទៅទំព័រទី ០៩**






តមកពីទំព័រទី ០៨

# ទីក្រុងបើកឡើងវិញនៅថ្ងៃទី២៩ឧសភា

ឥឡូវនេះបើកលក់ទំនិញវិញហើយ នាសប្តាហ៍នេះ ។ ផ្ទុយគ្នានឹងហាងលក់ម្ហូបឆ្អិនស្រាប់ "ហាងយ៉ាំមី Yammy" ដែលនៅទល់មុខគ្នាមិនទាន់បើកទ្វារនៅឡើយទេ មកទល់នឹងថ្ងៃទី១៥ឧសភា នេះ ។ ដូចគ្នានឹងផ្សារបាយ័ន គឺផ្សារឡាក់គី Asian នៅផ្លូវវ៉ៃសហ្វីត បានបិទទ្វារ១សប្តាហ៍ ឥឡូវបើកទ្វារវិញហើយ ។

៧-ហាងខ្មែរលក់បន្លែត្រីសាច់ Ocean Garden Market នៅផ្លូវ មីឌុលសិក នាក្បែរ




សាលាក្រុងឡូវែល, ក៏បានបើកដំណើរការឡើងវិញហើយ

៨-ហាង សំពៅមាស Grocery Sampou Meas មិនបានបិទទ្វាទេ ប៉ុន្តែហាង Grocery Bangkok នៅផ្លូវឆែមហ្វឺតវឺត មិនឆ្ងាយពីគ្នា បានបិទទ្វារមួយរយៈ ឥឡូវបើកទ្វារវិញហើយ ។

៩-ភោជនីយដ្ឋានពិភពថ្មីនៅឆ្ងាយពីគេបន្តិច នៅចុងផ្លូវ "ប្រេន" ក៏បានបិទទ្វារ ហើយឥឡូវបើកទ្វារទទួលភ្ញៀវវិញហើយ ។

១០-ហាង ភោជនីយដ្ឋានមេគង្គ នៅផ្លូវ




"ប្រ៉ៃតវេយ" បើកទ្វារវិញហើយ ដូចគ្នានឹង

១១-ហាងអាស៊ានថ្មី Grocery New




Asean ដែលជាហាងទើបបើកថ្មី ក៏ជួបប្រទះវិបត្តិ កូវិដ១៩ នៅក្បែរគ្នា ក៏ទើបនឹងបានបើកលក់ដូរវិញហើយដែរ ។ នៅតែហាងលក់ម្ហូបអាហារឆ្អិនហើយស្រាប់ "ហាងថ្មដារ"ទើបនឹងផ្តើមបើកកាលពីថ្ងៃសៅរ៍នេះតែប៉ុណ្ណោះទេ។

១២-ហាង អតីតបាត់ដំបង V Mart លក់ម្ហូបអាស៊ីមិនទាន់បើកនៅឡើយទេ នាថ្ងៃទី




១៥ឧសភា នេះ។

១៣-ភោជនីយដ្ឋាន សែនមនោរម្យ នៅជិតគ្នានឹងហាងម្ហូបចិន China Star បានបើកជារហូតមក បន្ទាប់ពីបិទបានបន្តិចមក តែសកម្មភាព គឺធ្វើដូចគ្នាទាំងអស់ មិនឱ្យមានភ្ញៀវមកអង្គុយហូបក្នុងហាងត្រូវរក្សាគម្លាត២ហ្វីត ពីមនុស្សម្នាក់ទៅម្នាក់ទៀត ត្រូវពាក់របាំងមុខផង។

នៅពេលបើកសកម្មភាពរដ្ឋម៉ាសាឈូសិតឱ្យមកដូចដើមវិញហើយនោះ "ពាណិជ្ជកម្មមិនចាំបាច់" ដូចជាជាងកាត់សក់ ជាងធ្វើក្រចកក៏ដំណើរការមកវិញបាន, ជាងធ្វើ ឬជួសជុលរថយន្តជាងធ្វើទូរស័ព្ទ អ្នកលក់ខោអាវ លក់វត្ថុអនុស្សាវរីយកន្លែងហាត់ប្រាណ...នឹងចាប់ផ្តើមដំណើរការមកវិញហើយ ។

នឹងមានមនុស្សចេញដើរព្រោងព្រាត តាមផ្លូវទីប្រជុំជននឹងសម្បូរកិច្ចប្រជុំតាមទូរស័ព្ទ តែត្រូវគោរពគោលការ នៅឆ្ងាយពីគ្នា "២ហ្វីត" ត្រូវពាក់ម៉ាស់ នៅគ្រប់ទីកន្លែង ទោះជានៅការិយាល័យរដ្ឋបាលក៏ដោយ ។

វិស័យពាណិជ្ជកម្មបានត្រូវគេព្រមានថានឹងមិនងើបឡើងរួចភ្លាមៗនោះទេ អាចនឹងមានវិបត្តិសេដ្ឋកិច្ច រឹតតែធ្ងន់ធ្ងរ នៅថ្ងៃខាងមុខនៅឡើយ ។ ដើម្បីទប់ស្កាត់វិបត្តិនោះ សភានឹងរដ្ឋាភិបាលអាមេរិកកាំងគិតថា នឹងផ្តល់ជំនួយ Stimullus ថ្មីទៀតឱ្យដល់ប្រជាពលរដ្ឋអាចមានប្រាក់ចាយវាយឱ្យម្ចាស់ពាណិជ្ជកម្មអាចទប់ទល់ការខាតបង់ ហើយរក្សា "ប៊ីសនីស" ខ្លួនកុំឱ្យរលំបាន។

នៅថ្ងៃសៅរ៍ ទី១៦នេះ សេចក្តីរាយការពីក្រុងបូស្តុននិយាយថាអ្នកឆ្លងជម្ងឺថ្មីមាន១៥១២នាក់ នឹងស្លាប់ថ្មី១១៣នាក់ ដែលចំនួនមនុស្សស្លាប់សរុបនៅរដ្ឋម៉ាសាឈូសិតឡើងដល់៥,៧០៥នាក់ហើយ គឺជាចំនួនដ៏ច្រើន ចំណាតថ្នាក់ទី៣ នៅក្នុងប្រទេសដែលគេវាយតម្លៃថា ជារដ្ឋក្រីក្រនៅមានអ្នកទៅធ្វើការរោងចក្រច្រើន, មនុស្សចាស់ដែលទទួលការថែរទាំមិនបានដិតដល់ក៏ច្រើន...។

DAN O'BRIEN | DAN O'BRIEN

សូមស្វាគមន៍ និងសូមមកកាន់ភ្នាក់ងារលក់ ដើម្បីទិញរថយន្តថ្មីរបស់អ្នកនៅថ្ងៃនេះ! យើងមានការបញ្ចុះតម្លៃរាប់រយគ្រឿងនៃរថយន្តថ្មី និងរថយន្តប្រើប្រាស់រួចៗ ដូចជា sedans, jeeps, និង mini vans នៅក្នុងស្តុករបស់យើងៗ ទស្សនាទីតាំងរបស់យើងដែលនៅជិតអ្នកបំផុត ឬទូរស័ព្ទ វុទ្ធី យក់ សសម្រាប់រត់ជួប



Vuthy Yok វុទ្ធី យក់
Sales and Leasing Consultant
Office (978) 746-2500 Ext. 58316
Cell (978) 621-3842
vyok@danobrienautogroup.com




- One Year Maintenance Included
- One Year Paintless Dent Repair
- Free Safety Inspections for you and your entire household
- Lifetime Power-train Warranty

DAN O'BRIEN NISSAN
95 DRUM HILL ROAD,
CHELMSFORD, MA 01824
http://www.DanOBrienNissan.com

DAN O'BRIEN CDJR
175 PELHAM ST,
METHUEN, MA 01844
https://www.danobriencdjr.com

## KhmerPost USA, LLC
## សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



អគ្គនាយក សុបិន្ត ពិន
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com



និពន្ធនាយកខ្មែរ Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com



Richard Howe Jr.
Contributed Writer | Editor

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com
ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

**PRINT READERSHIP**

*50,000 Monthly / 600,000 Annually*
*Plus additional exposure in our online editions at khmerpostusa.com*

KhmerPost USA

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

# 2020 PRINTING SCHEDULES

## EFFECTIVE FEBRUARY 1, 2020

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue<br>5% Savings | 3 Months (6 Issues)<br>7.5% Savings | 6 Months (12 Issues)<br>10% Savings | 12 Months (24 Issues) |
|---|---|---|---|---|
| **Full** (10" wide x 13" tall) | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" wide x 6.5" tall) | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" wide x 6.5" tall) | 165 | 940 | 1831 | 3,564 |
| **1/8** (5" wide x 3.25" tall) | 90 | 513 | 999 | 1,944 |

**Your ad is also published in our online editions of the newspaper at khmerpostusa.com**




### MONTHLY DISTRIBUTION

***70+ Locations in Lowell, MA • 7,000 copies***
***25 Locations in Lynn & Revere, MA • 1,000 copies***
***25 Locations in Providence & Cranston, RI • 2,000 copies***
***Additional distribution online***

### *Khmer Post USA Distribution Locations Include:*

*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

| 2020 PRINTING DATES | ADVERTISING DEADLINE |
|---|---|
| February 15 -Friday | February 13- Thursday |
| February 29 -Saturday | February 28-Friday |
| March 09 -Monday | March 6 - Friday |
| March 23 -Monday | March 20 - Friday |
| April 06 -Monday | April 3 - Friday |
| April 20 -Monday | April 17 - Friday |
| May 04 -Monday | May 1 - Friday |
| May 18 -Monday | May 15 - Friday |
| June 1 - Monday | May 29 - Friday |
| June 15 - Monday | June 10 - Wednesday |
| July 1 - Wednesday | June 26 - Friday |
| July 15 - Wednesday | July 10 - Friday |
| August 1 - Saturday | July 27- Monday |
| August 15 - Saturday | August 10 - Monday |
| September 1 - Tuesday | August 27 - Thursday |
| September 15 - Tuesday | September 10 - Thursday |
| October 1 - Thursday | September 26 - Saturday |
| October 15 - Thursday | October 10 -Saturday |
| November 1 - Sunday | October 27 - Tuesday |
| November 15 - Sunday | November 10 - Tuesday |
| December 1 - Tuesday | November 25 - Wednesday |
| December 15 - Tuesday | December 10 - Thursday |

***Advertising deadlines are 5 business days prior to printing date.***

### CONTACT INFO

**27 Jackson Street • Unit 329 • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092**
**Email: khmerpostusa@gmail.com**
**www.khmerpostusa.com**

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

Follow us @KhmerPostUSA

Follow us @KhmerPostUSA

តមកពីទំព័រទី ០២

# ប្រទេសចិនធ្លាក់ក្នុងវិបត្តិនៅពេល...

នៅតាមប្រទេសទន់ខ្សោយ ដោយការដឹកនាំទំនិញរបស់ចិនដោយការចេញចូលរបស់ជំនាញការចិន ដែលបានបង្កើនអំពើពុករលួយក្នុងចំណោមមន្ត្រីក្នុងប្រទេសដែលខ្លួនឆ្លងកាត់បង្កើនការជំពាក់លុយចិនកាន់តែច្រើនទៅៗ។

ស្រាប់តែ"កូវីដ១៩"ក៏ផ្ទុះចេញពីប្រទេសចិន ដោយចៃដន្យពីទីក្រុងវូហាន នាចុងឆ្នាំ ២០១៩ ។

សេចក្តីរាយការខ្លះថា "ចិនបានបង្កើតមេអាសន្នរោគរាតត្បាត"នោះ រាប់ទាំងវេជ្ជបណ្ឌិតវង្វាន់ណូបែលជប៉ុនម្នាក់ ដែលធ្លាប់ធ្វើការនៅពេទ្យវូហានផង គាត់បានទម្លាយរឿងសម្ងាត់របស់ចិនទៀតផង។ ចិនបានលាក់លាមបិទបាំងការផ្ទុះជម្ងឺកូរ៉ូណាវ៉ាយរឹសយ៉ាងយូរ រហូតដល់ហួសពេលទប់ស្កាត់បានប្រកបដោយប្រសិទ្ធិភាព ហើយមេរោគនោះបានឆ្លងយ៉ាងលឿន ទៅប្រទេស ដែលមានទំនាក់ទំនងជាមួយប្រជាជនចិនច្រើនជាងគេ ។ មនុស្សបានស្លាប់រាប់លាននាក់ ហើយឆ្លងជម្ងឺនោះជាច្រើនលានថែមទៀតពាសពេញតែសាកលលោក ក៏ប៉ុន្តែសេចក្តីរាយការចេញពីប្រទេសកុម្មុយនិស្តចិន ប្រទេសកុម្មុយនិស្តឯទៀតៗ មានទាំងប្រទេសកម្ពុជាផង ដែលមានការប្រុងប្រយ័ត្នតិចតួច បែរជាមានស្លាប់តិចតួចទៅវិញ ដែលជាហេតុមិនគួរឱ្យជឿបាន។

នៅមហាសន្និបាតចិន នាសប្តាហ៍មុននេះ បានបង្ហាញថា ចិនទទួលស្គាល់ពីគុណវិបត្តិគ្រប់គ្រងសេដ្ឋកិច្ចរបស់"ផ្លូវសូត្រ" របស់ជំនួយចិនតាមរយៈប្រទេសមួយចំនួន ដែលមិនព្រមទទួលជំនួយពុករលួយ ហើយប្រឆាំងនឹងវត្តមានចិនក្រហម, ចិននៅតែមានមហិច្ឆិតាបង្ខំឱ្យចិនតាយវ៉ាន់ក្លាយជារណបរបស់ខ្លួន, បញ្ឈប់ ហុងកុងមិនឱ្យធ្វើបាតុកម្មតវ៉ា ប៉ុន្តែសេដ្ឋកិច្ចរបស់ចិន បាន



នាវាចម្បាំងរបស់ចិន

ធ្លាក់ចុះដុនដាបខ្លាំងណាស់ទៅហើយ។ នៅសេរីលង្ការ ចិនបានឱ្យខ្ចីប្រាក់ច្រើនពេក រហូតដល់សងវិញមិនបាន ក៏ប្រគល់ដែនដីជាកំពុងផែនឹងដែនសមុទ្រឱ្យទៅចិន ដែលគេយកទៅធ្វើជាតំបន់យុទ្ធសាស្ត្រចិនបាត់ទៅ... នៅកម្ពុជាចិនមិនត្រឹមតែយកកោះកុងសម្រាប់ដាក់ទ័ពទេ ថែមទាំងជីកកកាយយករ៉ែ ឬរាប់ឆ្នាំ យ៉ាងសុសដី... ។ល។

ប្រទេសម្ចាស់ទំនិញបន្ថយការបញ្ជាទិញពីគ្រប់កន្លែងមានអាមេរិក អឺរ៉ុប គេមានការមិនសប្បាយចិត្ត នឹងទង្វើរបស់នយោបាយចិន, គេចង់សងសឹក, គេចង់ទប់ស្កាត់ដំណើររបស់ចិននៅសមុទ្រចិន ខាងត្បូង, គេចង់ទប់ស្កាត់ចិនចំពោះការដាក់ទីតាំងកងទ័ព នៅប្រទេសនានា, គេបានគម្រាមចិនពីការយកកោះ នឹងកំពុងផែនៃប្រទេសមានសមុទ្រ ធ្វើជាតំបន់យុទ្ធសាស្ត្រចិន, ចិនទិញក្បាល់ថ្នាក់ដឹក នាំរដ្ឋាភិបាល ប្រទេសក្រីក្រឱ្យបំរើចិន ហើយសម្លាប់ជាតិគេតែម្តង, ដូចគំរូនៅកម្ពុជា ជាមួយសម្តេច សីហនុ ជាមួយប៉ុលពត នឹងជាមួយគ្រួសារ ក្រកូល ហ៊ុន សែន ជាដើម ។

ប្រទេសមហាអំណាចសេដ្ឋកិច្ចពិភពលោក គេមានវិធានការចង់បញ្ឈប់ទំនាក់ទំនងសេដ្ឋកិច្ចជាមួយចិន បន្ទាប់ពី"កូវិដ១៩", គេចង់ដកយករោងចក្រត្រឡប់មកប្រទេសគេវិញ, គេចង់បង្វែដាក់ការបញ្ជាទិញ ទៅឱ្យប្រទេសដែលគ្មានល្បិចកាចសាហាវវិញ ដូចជាទៅកាន់ប្រទេសឥណ្ឌា ដែលក្រតែ"ស្បាហ៏នឹងទៀងត្រង់..ដូច្នេះចិនអាចនឹងដាច់ស្បៀង ។

ប្រទេសចិន ជាប្រទេសដែលមាននយោបាយជា"បីសាច"ដណ្តើមយកសេចក្តីសុខពីប្រទេសដ៏ទៃ ដោយមិនបារម្ភពីអាយុជីវិតនៃប្រទេសណាទេ ពីព្រោះតែមហិច្ឆិតាជាមហាអំណាច ជាអ្នកបញ្ជាជាម្ចាស់នៃពិភពលោក ដោយមិនប្រមាណកម្លាំងនៃប្រជាជាតិរបស់ខ្លួននោះទេ ។ ហេតុនោះហើយ បានជានៅពេល ដែលគេព្រួតគ្នាវាយបកមកវិញ ដែលអាចក្លាយទៅជាសង្គ្រាមលោកលើកទី៣មែន ប៉ុន្តែប្រទេសចិននឹង រលាយតែម្នាក់ឯង សូម្បីតែប្រទេសកុម្មុយនីស្តដូចគ្នាមានវៀតណាម នឹងរុស្ស៊ី ក៏មិនមានបំណង ជួយគាំទ្រចិនដែរ ។






តមកពីទំព័រទី ០៥

# អត្ថប្រយោជន៍ភាពគ្មានការងារធ្វើ

*អ្នកត្រូវតែដាក់បណ្តឹងឧទ្ធរណ៍ក្នុងកំឡុងពេល ៣០ ថ្ងៃប្រតិទិន នៃកាលបរិច្ឆេទនៃការដកសិទ្ធិ ។*

វាជាការសំខាន់ណាស់ដែលអ្នកចូលរួមក្នុងសវនាការដែលបានគ្រោងទុកនៅពេល ដែលសនវការនឹងមានលទ្ធផលជាសេចក្តីសំរេចថ្មីលើសិទ្ធិរបស់អ្នក ។

ប្រសិនបើអ្នកនៅតែមិនទាន់មានការងារធ្វើ ខណៈពេលរង់ចាំសវនាការអ្នកត្រូវតែបន្តស្នើសុំការទូទាត់សំណងអត្ថប្រយោជន៍រៀងរាល់សប្តាហ៍ ។ បើទោះបីជាការប្តេជ្ញាចិត្តដំបូងរបស់អ្នកត្រូវបានដាក់បញ្ច្រាសក៏ដោយ អ្នកនឹងមិនទទួលបានការទូទាត់អត្ថប្រយោជន៍ សម្រាប់សប្តាហ៍ នៅពេលដែលអ្នកមិនបានស្នើសុំអត្ថប្រយោជន៍ ។

**សវនាការ**

នៅពេលដែលនាយកដ្ឋានសវនាការ (Hearning Department) ទទួលបានបណ្តឹងឧទ្ធរណ៍វានឹងត្រូវបានគ្រោងសម្រាប់សវនាការ ហើយអ្នកនឹងត្រូវបានផ្ញើសេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទ និងពេលវេលា ។ រីតទាល់តែការិយាល័យ DUA ត្រូវបានបើកជាសាធារណៈជនវិញ សវនាការនឹងធ្វើឡើងតាមទូរស័ព្ទ ។

សវានាការត្រូវបានត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យ ។ បន្ទាប់ពីសវការអ្នកត្រួតពិនិត្យពិនិត្យឡើងវិញ នឹងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយផ្អែកលើឯកសារនឹងព័តិមានដែលបង្ហាញនៅសវានាការ ។

**ក្រុមប្រឹក្សាភិបាលពិនិត្យឡើងវិញនៃនាយកដ្ឋានជំនួយការគ្មានការងារធ្វើ**

ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសំរេចរបស់អ្នកត្រួតពិនិត្យ ពិនិត្យឡើងវិញអ្នកមានពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃផ្ញើសេចក្តីសំរេចនោះ ដើម្បីប្តឹងឧទ្ធរណ៍ទៅក្រុមប្រឹក្សាភិបាលពិនិត្យឡើងវិញ ។

ប្រសិនបើក្រុមប្រឹក្សាភិបាលពិនិត្យមើលករណីនេះ ដើម្បីធ្វើការពិនិត្យឡើងវិញ វានឹងធ្វើការសម្រេចចិត្តដោយប្រើសម្ភារៈករណីដែលទទួលបានពីនាយកដ្ឋានសវនាការរួមទាំងសវនាការ ដែលបានកត់ត្រាទុក ។ នៅពេលក្រុមប្រឹក្សាភិបាលពិនិត្យសេចក្តីសំរេចវាផ្តល់សេចក្តីណែនាំអំពីវិធីប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសំរេចចិត្តនេះ តុលាការមណ្ឌល (District Court) ឬតុលាក្រុងបូស្តុន (Boston Municipal Court) ។ អ្នកក៏អាចប្តឹងឧទ្ធរណ៍ទៅតុលាការស្រុក ឬតុលាការក្រុងបូស្តុន ប្រសិនបើក្រុមប្រឹក្សាភិបាលបដិសេធមិនទទួលយកករណីនេះមកពិនិត្យ ។ អ្នកមានពេលសាមសិបថ្ងៃគិតចាប់ពីថ្ងៃផ្ញើសារនៃសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ឬការបដិសេធនៃការពិនិត្យមើល ដើម្បីដាក់បណ្តឹងឧទ្ធរណ៍របស់តុលាការ ។

ដើម្បីដឹងបន្ថែមទៀតអំពីការពិនិត្យឡើងវិញនៃក្រុមប្រឹក្សា រ៉ូមចូលទៅ WWW.mass.gov/dua/bor .ដើម្បីស្វែងយល់បន្ថែមអំពីការប្តឹងឧទ្ធរណ៍ទៅតុលាការរួមទាំងថា តើត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍នៅក្នុងតុលាការស្រុក ឬតុលាការក្រុងបូស្តុន សូមមើលច្បាប់ទូទៅនៃរដ្ឋម៉ាសាជូសិតជំពូក 151A ផ្នែក ៤២ ។

**សិទ្ធិរបស់អ្នកចំពោះសំណាង**

ប្រសិនបើអ្នកចង់ឱ្យមានកំណាងនៅក្នុងកម្រិតណាមួយនៃបណ្តឹងឧទ្ធរណ៍វាជាការសំខាន់ដែលត្រូវរៀបចំតំណាងឱ្យបានឆាប់តាម ដែលអាចធ្វើទៅបាន ។ ភ្នាក់ងារដែលមានការអនុញ្ញាតនៃជម្រើសរបស់អ្នក ដូចជា មេធាវី ឬអ្នកតស៊ូមតិអាចតំណាងឱ្យអ្នកនៅគ្រប់កំរិតនៃបណ្តឹងឧទ្ធរណ៍របស់ទីភ្នាក់ងារ ។ ទាក់ទងសមាគមក្រមវិទ្យាក្នុងតំបន់របស់អ្នក ឬអង្គការតស៊ូមតិផ្នែកច្បាប់ ដើម្បីសុំជំនួយ ។ DUA មិនអាចណែនាំ ឬចាត់តាំងអ្នកតំណាងបានទេ ។

Continued from Page 05

# PANDEMIC UNEMPLOYMENT ASSISTANCE BENEFITS

the case for review. You have thirty days from the mailing date of the Board's decision or denial of review to file a court appeal.

To learn more about the Board of Review, go to www.mass.gov/dua/bor. To learn more about appealing to court, including whether to file your appeal in the District Court or the Boston Municipal Court, see Massachusetts General Laws Chapter 151A, Section 42.

**Your right to representation**

If you wish to be represented at any level of appeal, it is important that you arrange representation as soon as possible. An authorized agent of your choice, such as an attorney or advocate, may represent you at any level of agency appeal. Contact your local bar association or a legal advocacy organization for assistance. DUA cannot recommend or appoint a representative.



សភាតំណាងរាស្ត្រទើបបញ្ចេញច្បាប់ជួយដល់អ្នករងគ្រោះដោយកូវីត១៩


សមាគម"អាសេឡិច"មានអ្នកជួយធ្វើសំណុំរឿងជួយដល់អ្នកអត់ការធ្វើ

-ពាណិជ្ជករចង់បានប្រាក់ជំនួយជាប្រាក់កម្ចីរបស់រដ្ឋ និងជួយដល់អ្នកដែលមិនបានទទួលស្ទីមេលីស និងឯកសាររដ្ឋបាលផ្សេងៗទៀត

សូមទូរស័ព្ទមកសមាគម "អាសេឡិច" ទូរស័ព្ទលេខ 978-942-8490

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត

URBAN REAL ESTATE

មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន

Residential Leasing Center



ដាញ៉េល តាន

ភ្នាក់ងារអចលនៈទ្រព្យ

Daniel Tan

Real Estate Agent

Cell: 978-902-6354

508 Westford Street • Lowell, MA 01851

(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនសួរិន អេជេនស៊ី

KK Insurance Agency, Inc.

រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម

Car • Home • Business



508 Westford Street

Lowell, MA 01851

978-970-2212

kk@kkinsurancema.com

## តមកពីទំព័រទី ០៧ លោក ហ៊ុន សែន ពុំបានធ្វើសង្គ្រាមរួម

ដោយសារមិនបញ្ឈប់ការរំលោភដែនសមុទ្រ នឹងដែនដីរបស់ខ្លួនប្រទេសចិនកំពុងតែទទួលសំពាធស្ទើរបែកពោះសង្វិតរបស់ខ្លួន ពីសហរដ្ឋអាមេរិកពីសហភាពអឺរ៉ុប ពីឥណ្ឌា ពី អូស្ត្រាលី...។ ដែលបានបណ្តាលឱ្យ"ផ្លូវសូត្រចិន"រាយប៉ាយពាសពេញពិភពលោក ក៏ក្លាយទៅជាស្វិតក្រជីវដូចគ្នា រកស៊ីដឹកទំនិញលែងបាន ដោយកូវីដ ១៩ បានស៊ីរូងផ្តើមពីប្រទេសចិនមុនគេ។ គ្មាននរណាជឿសេចក្តីប្រកាសព័ត៌មានពីការទប់ស្កាត់ជម្ងឺអាសន្នរោគរបស់ចិននោះដូចគ្នានឹងនៅស្រុកខ្មែរដែរ ដូច្នេះក៏គ្មាននរណាហក់ទៅជួយចិនបាននោះទេ, រីឯអ្នកសង្ឃឹនថា ចិន នឹងមកជួយ ក៏កំពុងតែប្រឈមមុខនឹងការបះបោរនៅក្នុងប្រទេសទាំងពីរជាមិនខាន ។

**ហេតុអ្វីក៏ ហ៊ុន សែន ខកខានមិនបានធ្វើសង្គ្រាមរួមជាមួយខ្មែរ?**

ពីព្រោះតែលោកត្រូវធ្វើសង្គ្រាមប្រឆាំងនឹងព្រះអង្គម្ចាស់ជាព្រះរាជបុត្រសម្តេចនរោត្តម សីហនុ គឺព្រះមហាក្សត្របច្ចុប្បន្ន ដែលមិនត្រឹមតែស្នងរាជ្យនៅកម្ពុជាទេ តែនៅតែជាទំនុកចិត្តគ្មានប្តូររបស់រដ្ឋអំណាចចិនថែមទៀត។

ឆ្លៀតឱកាសដែលចិនរងការវាយប្រហារពីគ្រប់ជ្រុងជ្រោយលោក ហ៊ុន សែន បានធ្វើ"នយោបាយជាន់ទាប" ជាអ្នកបំរើចិន ខំលើកមុខចិន ដូចជាអ្នក"ខាត់ស្បែកជើងឱ្យចិន"ខាតប្រយោជន៍ប្រទេសខ្លួនឯង ហើយពុំបានចំណេញអ្វីដល់ចិនថែមទៀត។

ការដណ្តើមកន្លែងដេកកណ្តាលរបស់ ហ៊ុន សែន ពេលនេះមិនដូចរជ្ជកាលសម្តេច សីហនុទេ ពីព្រោះព្រះអង្គធ្វើ"នយោបាយជាន់ខ្ពស់"គាពារចិនក្នុងនាមជាមនុស្សដែលចិនត្រូវការបំផុត ដែលអ្នកការទូតគេអាចយល់បានថា"ជាអ្នកនយោបាយដែលមិនសម្លាប់ខ្លួនដើម្បីបរទេស" នោះទេ ។ ហេតុនេះហើយ បានជាពេលនេះ ព្រះរាជបុត្រ សីហមុនី គង់ប្រថាប់នៅក្រុងចិន ពីព្រោះប្រសិនបើលោក ហ៊ុន សែន ធ្លាក់ទឹក គឺអ្វីទាំងអស់ នឹងធ្លាក់ក្នុងព្រះហស្ថព្រះរាជបុត្រដោយមិនចាំបាច់ប្រឹងដែរ ។លើចំណុចនេះ ហើយដែលប្រទេសវៀតណាម គេដាក់ទ័ពតាមព្រំប្រទល់ដែន នៅពេលដែល"កម្ពុជាប្រកាសភាពអាសន្ន" ពីព្រោះតែ"គ្រោះថ្នាក់ដ៏គួរឱ្យបារម្ភនោះ វាមកពីប៉ែកាំង"ឯណោះទេ។ ចំណែកឯ ហ៊ុន សែន បែរជាដាក់ប្រទេសខ្លួន ក្នុងភាពអាសន្ន ដើម្បីពង្រឹងច្បាប់ចរាចរ តើជាការគួរដែរឬទេ ?



នេះជាការភ្លាត់ស្នៀតរបស់ ហ៊ុន សែន ដ៏ធំមួយទៀតហើយ ដែលបំរើចិនហើយមិនបានក្លាយជាមិត្ត តែនៅតែជាអ្នកបំរើដដែលខូចទាំងប្រយោជន៍ជាតិខ្មែរ នឹងប្រយោជន៍បក្សប្រជាជនថែមទៀត ។

## ដំណឹងមរណទុក្ខសព
## លោកស្រី សំណាង លន និងលោក ប៉ោ ហេង

ដំណឹងដ៏ក្រៀមក្រំនេះបានកើតឡើង នៅពេលដែលលោកតា ហេង ប៉ោ អាចារ្យវត្តពន្លឺពុទ្ធចក្រ បានទទួលមរណភាពនៅថ្ងៃទី១៧ ឧសភា ២០២០, មិនបានមួយថ្ងៃផង លោកស្រី សំណាង លន ជាភរិយា និងជាជំនួយជើងវត្តដដែល ក៏ទទួលមរណភាពម្នាក់ទៀតថ្ងៃ១៨ បន្ទាប់មកនៅ "មន្ទីរពេទ្យឡូជេនរ៉ល" ។ ពួកគាត់រងគ្រោះដោយជម្ងឺ "កូវីដ១៩"ដែលកំពុងតែរាតត្បាតលើពិភពលោកយើងនេះ ។




អ្នកទាំងពីរជាអ្នកស្រុកបាត់ដំបង ហើយមកដល់រស់នៅសហរដ្ឋអាមេរិកនេះ តាំងពីឆ្នាំ១៩៨១ គឺជាមាតាបីតារបស់ សារា ឃុន ឡេង និង សេរីវុឌ្ឍ ឃុន ជាអកុសល សេរីវុឌ្ឍ បានបាត់បង់ជីវិតកាលពីថ្ងៃទី៤ មេសា ២០១៩ ដោយជម្ងឺមហារីក ។

បន្ថែមពីញាតិរបស់កូនស្រី សារា ដែលកំពុងមានទុក្ខព្រួយនៅមានជីដូនលោកយាយ ហួត ហាក់, កូនប្រសារ ប្រុស ខេវិន ឡេង, កូនប្រសារស្រីគាត់ វ៉ាណេយ៉ា ឃុន, រួមទាំងចៅប្រុសពីរនាក់ទៀតគឺ ទ្រីស្តង់ នឹង អ៊ីវ៉ាន់ ឡេង, និងក្រុមគ្រួសារសាច់ញាតិជាច្រើនទៀតដែលកំពុងរស់នៅអាមេរិក, កម្ពុជានិងនៅជប៉ុន ។

លោកតា ហេង និងលោកស្រី សំណាង ស្រឡាញ់គ្រួសារនិងមិត្តភក្រ្តលោកណាស់ ហើយក៏ទទួលការគោរពរាប់អានពីញាតិមិត្តវិញគ្រប់ៗគ្នាដែរ ។ ពួកគាត់ជាមនុស្សចិត្តសទ្ធា, រាក់ទាក់ ហើយត្រៀមខ្លួនជានិច្ច នឹងជួយអ្នកដ៏ទៃដែលត្រូវការគាត់, ដែលនោះហើយគឺជាឧត្តមគតិ នឹងជំនឿដ៏រឹងមាំលើព្រះពុទ្ធសាសនា ។ គាត់ជាអ្នកប្រារព្ធសាសនានឹងបរិច្ចាគទាន ព្រមទាំងជឿទៅលើកម្មផលនឹងសងគុណដល់សហគមន៍វិញ, ហើយតែងតែរកផ្លូវជួយដល់មាតុភូមិកំណើតគាត់ជានិច្ចជាកាល ដូចជាសង់វិហារ ជីកអណ្តូង ទឹកស្អាតគាំទ្រសាលារៀន នឹងវែរអង្គាសប្រាក់ ដើម្បីជួយខេត្តណាដែលខ្វះខាតជាដើម ។

**កម្មវិធីឈាបណកិច្ចៈ ថ្ងៃសៅរ៍ ទី ២៣ ឧសភា ២០២០**

ម៉ោង៧,៤៥ព្រឹកៈ ជួបជុំគ្នានៅ Fay McCabe Funeral Home, 105 Moore St. Lowell, MA ។

សូមនៅក្នុងរថយន្តលោកអ្នក រហូតដល់មានគេមកអញ្ជើញឱ្យទៅចូលជួរទៅគោរពសព

ម៉ោង ៨,០០ព្រឹកៈ ចេញដំណើរពី Fay McCabe Funeral Home, Lowell ទៅកាន់ឈាបនដ្ឋាន ស្ថិតនៅ Linwood Crematory 41 John Ward Ave. Haverhill, MA ព័ត៌មានបន្ថែម សូមអញ្ជើញទាក់ទងៈ សារ៉ា ឃុន ឡេង (978)835 3129 និង វ៉ាណេយ៉ា ឃុន (978) 805 8821 ។

*សូមអរគុណ!*


ការិយាល័យ មេធាវី
ចំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com


## តមកពីទំព័រទី ០៤ កម្ពុជាផ្ញើកំណត់ទូតទៅវៀតណាម...

ការប្រជាជនខេត្តអានយ៉ាងបានពន្យល់ អភិបាលខេត្តកណ្តាលអំពីវិធានការរបស់ខ្លួនទប់ស្កាត់ការឆ្លងដែនចូលដោយខុសច្បាប់ និងការបង្ការការចម្លងជំងឺកូវីដ១៩។ ទោះជាយ៉ាងណា លោកអះអាងថា ខេត្តអានយ៉ាងបានធ្វើការណែនាំដល់កងកម្លាំងមានសមត្ថកិច្ចឱ្យធ្វើការរើចេញនូវបណ្តាទីតាំង ធ្វើពីតង់កៅស៊ូនេះទាំងអស់ដែលជាប់ព្រំដែនជាមួយខេត្តកណ្តាល ហើយជាមូលដ្ឋាន ការរើចេញនូវបណ្តាទីតាំងបញ្ហាការនេះ គឺមិនប៉ះពាល់ដល់ការងារគ្រប់គ្រងព្រំដែន និងការត្រួតពិនិត្យបង្ការការឆ្លងជំងឺកូវីដ១៩ នោះទេ។ ទោះជាយ៉ាងនេះក្តី បើតាមរបាយការណ៍ចុងក្រោយ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបានព្រឹកថ្ងៃទី២៣ ខែឧសភានេះគឺភាគីវៀតណាមទើបតែបានរុះរើ នៅតង់ទីតាំងយោធាចេញចំនួន៣ទីតាំងតែប៉ុណ្ណោះ មិនទាន់មានការរុះរើបន្ថែមទៀតឡើយ ចំណែកការងារនៅតាមបណ្តោយព្រំដែនរវាងប្រទេសទាំងពីរមានកិច្ចសហប្រតិបត្តិការទៅវិញទៅមកជាធម្មតា។

ដោយ Fresh News

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

**ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។**

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- *រស់នៅផ្ទះរដ្ឋ*
- *អាយុ ២២ ឆ្នាំឡើងទៅ*
- *មាសហែលស្តង់ដា*

**ផលប្រយោជន៍ទទួលបាន :**

- *ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក២៤ម៉ោង*

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

**Benefits you will get:**

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ដើម្បីចុះឈ្មោះសូមទាក់ទងមក
## To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

"អត្ថបទស្រាវជ្រាវប្រវត្តិសាស្ត្រ"

# ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ"ខេជីអេ"

## អវសាន្តនៃសមាគម KJA Khmer Journalists Association

(KJA = Khmer Journalist Association )

ដោយ ពិន សំខុន **តពីលេខមុន**

គ្នាយ៉ាងចាស់ដៃតទល់គ្នានឹងអង្គភាពព័ត៌មានគណបក្សប្រជាជន ដែលមានប្រមាណជា ១០០ រាប់ទាំងអង្គភាពរដ្ឋផង ។ ទ្រង់ទ្រាយនៃប្រព័ន្ធគ្រប់គ្រងនយោបាយពេលនោះ គឺសម្ព័ន្ធភាពរវាងគណបក្សហ៊្វុនសិនប៊ិចនឹងគណបក្សប្រជាជនកម្ពុជាកំពុងតែប្រេះឆាយ៉ាងចំហរ រីឯគណបក្សជាតិខ្មែរ ក៏កំពុងតែដុតបន្ថែមលើការបែកបាក់នេះយ៉ាងចាស់ដៃដែរ ។ ថ្ងៃទី១៨ ឧសភា ១៩៩៦ អ្នកកាសែតមនសិការខ្មែរ ឈ្មោះ ធន់ ប៊ុនលី មាននិន្នាការខាងលោក សម រង្ស៊ី បានត្រូវជនជិះម៉ូតូ២នាក់ បាញ់ស្លាប់នៅមុខប៉ុស្តិ៍ប៉ូលិសដោយរកឃាដករមិនឃើញ។ ប៊ុនលី មុននឹងស្លាប់បានទទួលការព្រមានផ្ទាល់មាត់ពី ពិន សំខុន នៅទីស្នាក់ការសមាគមមុនគេបាញ់១ ថ្ងៃថា កុំឱ្យប្រើពាក្យជេប្រមាថខ្លាំងៗលើភរិយាលោក ហ៊ុន សែន ដែលអាចនាំឱ្យគ្រោះថ្នាក់តែអត់ប្រយោជន៏។ នេះជាការធ្វើឃាដអ្នកកាសែតជាលើកទី៤ បន្ទាប់ពីមានការសម្លាប់ ដោយបំផ្ទុះគ្រាប់បែកនៅទីស្នាក់ការវិទ្យុហ៊្វុនស៊ិន


អ្នកកាសែត យឹម រតនា ទទួលទោសជាប់ពន្ធនាគារ១ឆ្នាំដោយ អត្ថបទវិភាគនយោបាយ

ប៊ិច នៅប៉ុន្មានខែមុនបណ្តាលឱ្យស្លាប់អ្នកកាសែតម្នាក់ឈ្មោះ ឯក មង្គល ។

ទោះជាមានអសន្តិសុខក្តីសមាគមនៅតែទៅជួយលើកទឹកចិត្តសមាជិកអ្នកសារព័ត៌មានយ៉ាងសកម្មដដែល ។ នៅពេលជាមួយគ្នានោះ នាយកកាសែត យឹម រតនា បានត្រូវតុលាការ បានត្រូវតុលាការខ្មែរ ដាក់ទោសជាប់គុក១ឆ្នាំ, ដោយសារអត្ថបទ"ប្រទេសខ្មែរជាស្រុកចោរ" ហើយ ក៏មាននាយកកាសែតម្នាក់ទៀត របស់ដំណឹងពេលព្រឹកគឺនួននន់ក៏ត្រូវតុលាការដដែលដាក់គុក១ឆ្នាំដែរដោយសារអត្ថបទធ្វើឱ្យទាហ៊ាន


លោក សម រង្ស៊ី សាងភ្នួស១ខែ មុននឹងបន្តសកម្មភាពនយោបាយសកម្ម

បះបោរ...នៅមានអ្នកកាសែតប្រឆាំងម្នាក់ទៀត ឈ្មោះ ហែម វិភាគ ក៏ត្រូវជាប់គុក១ឆ្នាំដែរ ដោយបុព្វហេតុប្រឆាំងនឹងរដ្ឋាភិបាលពុករលួយ... តែរៀងរាល់ពេល ដែលមានអ្នកកាសែតរងគ្រោះដោយអយុត្តិធមិ សមាគមតែងបានធ្វើសកម្មភាពការពារឱ្យមានការដោះលែងមកវិញ ក្នុងរយពេលតិចជាង១ខែ យ៉ាងជោគជ័យ ដោយការស្នើសុំព្រះមហាក្សត្រ សូមព្រះអង្គព្រះរាជទាន"ការលើកលែងទោស" នឹងបញ្ជូនព័ត៌មានទៅបណ្តាញព័ត៌មានអន្តរជាតិពីភាពអយុត្តិធមិ ចំពោះអ្នកកាសែតដែលគ្រាន់តែបញ្ចេញមតិលើទំព័រកាសែត។

នៅមានការគម្រាមកំហែងបែបផ្សេងទៀត ដោយកងប៉ូលិសលើកគ្នាពេញទាំងឡានទ្រុងបំរុងទៅកំទេចទីស្នាក់ការកាសែត ដែលសរសេរប៉ះពាក់មេ ឬក៏អង្គភាពសង្កាត់របស់ខ្លួន ។ អ្នកកាសែតទាំងនោះមិនបានឱបដៃឱ្យប៉ូលិសចូលមកកំទេចទីកន្លែងខ្លួននោះទេ, នៅទីស្នាក់ការកាសែតកោះសន្តិភាពនៅក្បែរស្តាតអូឡាំពិក របស់ ថុង អ៊ុយប៉ាង ដែលមាននិន្នាការខាងគណបក្សប្រជាជនទាំងបុគ្គលិកកាសែតទាំងប្រធានគេ បានកាន់កាំភ្លើងគ្រប់ដៃត្រៀមបាញ់ពីលើផ្ទះ៤ជាន់ រង់ចាំការមកដល់នៃកងប៉ូលីសប្រដាប់អាវុធ...។ នៅទីស្នាក់ការកាសែតយុវជនវិញ ក៏ដូចគ្នានាយក អ៊ូ សុវណ្ណ និន្នាការខាងគណបក្សជាតិខ្មែរ ក៏កាន់កាំភ្លើងតែម្នាក់ឯង នៅពីក្រោយរបាំង បាវដីខ្សាច់ ប្រថុយជីវិតទប់ទល់យកស្លាប់រស់តទល់នឹងកងប៉ូលីសចល័ត ដែលទំនងជាចង់មកកំទេចទីស្នាក់ការរស់គេដែរ... តែប្រធានសមាគម ពិន សំខុន ទទួលដំណឹងភ្លាមឱ្យដំណឹងតាម"អាយកូម" **នៅមានត**






# សូមបំពេញជំរឿនឆ្នាំ-2020 សម្រាប់សហគមន៍របស់យើង។



ជំរឿនឆ្នាំ 2020 គឺដើម្បីធ្វើការរាប់ចំនួនប្រជាពលរដ្ឋគ្រប់ៗរូប ដែលរស់នៅក្នុងសហរដ្ឋអាមេរិក។ សូមជួយបំពេញជំរឿននៅថ្ងៃនេះ ដើម្បីទទួលបានសេចក្តីជូនដំណឹងអំពីជំនួយរាប់ពាន់លានដុល្លារអាមេរិក នឹងជួយដល់គ្លីនិកសុខភាព សេវាសង្គ្រោះបន្ទាន់ និងវិស័យអប់រំជារៀងរាល់ឆ្នាំ សម្រាប់រយៈពេលដប់ឆ្នាំខាងមុខទៀតនេះ។
**សូមបំពេញជំរឿនតាមអនឡាញ ឬ តាមប្រអប់សំបុត្រ។ ដើម្បីស្វែងយល់ពីរបៀបបំពេញសូមមើលគេហទំព័រនេះ 2020CENSUS.GOV/km**

Shape your future START HERE >

United States® Census 2020

**2020CENSUS.GOV/km**

ឧបត្ថម្ភដោយ ក្រសួងជំរឿនប្រជាជនសហរដ្ឋអាមេរិក (U.S. Census Bureau)